# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

*********

## កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ ស្រ្តេត ប្រដាក់សិន ហ្គាម៉ិន ឯ.ក ជាមួយ
## តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ
## ស្តីពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០នាទីព្រឹក នៅក្នុងរោងចក្រ ស្រ្តេត ប្រដាក់សិន ឯ.ក មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ នឹងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយករោងចក្របានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្នរោងចក្រខ្វះការបញ្ជាទិញ ដែលបណ្តាលឱ្យច្រវាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះរោងចក្រសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៦១នាក់ (ស្រី ១២៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ១៦១នាក់ (ស្រី ១២៣នាក់) រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។ ក្នុងអំឡុងពេលព្យួរការងារនេះ កម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឧបត្ថម្ភ ចំនួន ៧៥ដុល្លា។ ក្នុងករណីមានការកែប្រែនូវលក្ខខណ្ឌណាមួយក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារដែរជាគោលការណ៍កំណត់ថ្មីរបស់អាជ្ញាធរមានសមត្ថកិច្ច (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) នោះការព្រមព្រៀងនឹងអនុវត្តតាមគោលការណ៍ថ្មីនោះ។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងានេះ និងបើកជូនបងប្អូនកម្មករនិយោជិតដូចខាងតទៅ៖

- លើកទី១ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ ចំនួន ៣០ដុល្លា
- លើកទី២ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ចំនួន ៤៥ដុល្លា។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១១:៣០នាទី ព្រឹកនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃសុក្រ ៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣

**នាយករោងចក្រ**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ស្រ្តេត ប្រដាក់សិន ហ្គាម៉ិន ឯ.ក
STRETCH PRODUCTION GARMENT CO., LTD.
KINGDOM OF CAMBODIA

Zhou Qun Zhen

**ស្នាមមេដៃតំណាងកម្មករ និយោជិក និងតំណាងសហជីព**